ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ

# រយៈពេល ៣ ឆ្នាំ

# (២០០៨-២០១០)

ឈ្មោះសហគមន៍នេសាទ : បែកចាន

ភូមិ : បែកចាន

ឃុំ : អំពិលទឹក

ស្រុក : កំពង់ត្រឡាច

ខេត្ត : កំពង់ឆ្នាំង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទ
# រយៈពេល ៣ ឆ្នាំ
# (២០០៨-២០១០)

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | បែកចាន |
| ភូមិ | : | បែកចាន |
| ឃុំ | : | អំពិលទឹក |
| ស្រុក | : | កំពង់ត្រឡាច |
| ខេត្ត | : | កំពង់ឆ្នាំង |

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១ ស្ថានភាពទូទៅ

សហគមន៍នេសាទ **បែកចាន** ត្រូវបានបង្កើតឡើង ដោយមហាសន្និបាតកំណើតដំបូងនៅថ្ងៃទី **១៣** ខែ **មិថុនា** ឆ្នាំ **២០០៧** និងបានធ្វើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ចុះថ្ងៃទី **១១** ខែ **មករា** ឆ្នាំ **២០០៨**។

សហគមន៍នេសាទ **បែកចាន** មានទីតាំងស្ថិតនៅក្នុង ភូមិ **បែកចាន** ឃុំ **អំពិលទឹក** ស្រុក **កំពង់ត្រឡាច** ខេត្ត **កំពង់ឆ្នាំង** ដែលមានសមាជិកសរុបចំនួន **៣១៨** នាក់ ស្រីចំនួន **២១០** នាក់ និងមានគណៈកម្មការចំនួន **១១** នាក់ ស្រីចំនួន **១** នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន **២២១** គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ ចុះល្បាតហើយបង្កើតតំបន់អភិរក្សផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ បានបោះឆ្នោតជ្រើសរើសគណៈកម្មការ បានបង្រៀនពីលក្ខន្តិកៈសហគមន៍នេសាទ និង ចុះឈ្មោះសមាជិកសហគមន៍នេសាទ បានបើកមហាសន្និបាទ ដល់ សមាជិកសហគមន៍ ធ្វើកិច្ច ព្រមព្រៀងសហគមន៍នេសាទ បានចុះល្បាតមួយខែបីដង ចុះត្រួតពិនិត្យមើលតំបន់អភិរក្ស បានទៅរៀននៅសៀមរាបលើគម្រោង៥ ឆ្នាំ បានត្រួតពិនិត្យបឹងទន្លេសាប បានរៀនផ្ទែកបរិស្ថាននៅ ខេត្តកំពង់ឆ្នាំង បានរៀនវគ្គការពារបរិស្ថាន និង ក្រុមព្រឹក្សាឃុំ និង សហគមន៍ វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិ បានចូលរួមជួយឧបត្ថម្ភ កសាងដូចជា ស្ពាន ទំនប់ សាលារៀន អាស្រម ជួយដល់ជនក្រៃក្រ។

## ២. អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ក -ប្រជាពលរដ្ឋ:

- ចំនួនប្រជាពលរដ្ឋក្នុងភូមិសរុបក្នុងសហគមន៍នេសាទមាន **៣១៨** នាក់ប្រុស **១០៨** នាក់ ស្រី **២១០** នាក់ ក្នុងនោះមានជនជាតិខ្មែរចំនួន **៣១៨** ខ្មែរឥស្លាមចំនួន **គ្មាន** អាណិកជនវៀតណាមចំនួន **គ្មាន**។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ៥៨ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ៧ នាក់ ស្រី ២ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៣១ នាក់ ស្រី ២៥ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ៣១ នាក់ ស្រី ២១ នាក់
- ចំនួនអ្នកមានជំងឺរាំរ៉ៃក្នុងសហគមន៍នេសាទមាន ១៨ នាក់ ស្រី ៩ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ **១០០%**។ ក្រៅពីនេះមានអ្នកកាន់សាសនា អ៊ីស្លាម ប្រមាណ **គ្មាន** សាសនាកាតូលិកប្រមាណ **គ្មាន**

- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន **៣០** នាក់ ស្រី **២០** នាក់កំរិតថ្នាក់បឋមសិក្សាចំនួន **៤១២** នាក់ស្រី **២៣៣** នាក់ កំរិតមធ្យមសិក្សា ចំនួន **២០២**នាក់ ស្រី **១២៣** នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាចំនួន **៩** នាក់ ស្រី **១** នាក់

**ខ -មុខរបរ**

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ១៩៦ គ្រួសារ
- ធ្វើស្រែចំនួន ២១៦ គ្រួសារ ទំហំ ៨៤៨ ហិកតា
- ជាងផ្ទះចំនួន ៤ គ្រួសារ
- ធ្វើសិប្បកម្មចំនួន ៨០ គ្រួសារ
- លក់ដូរ ចំនួន ១៦ គ្រួសារ

## ៣. កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក. ទីតាំង

កន្លែងនេសាទសហគមន៍ភូមិ **បែកចាន** ជាកន្លែងដែលត្រូវបានកាត់ចេញពីឡូត៍នេសាទលេខ **១៩** ដែននេសាទទឹកសាប ។

កន្លែងនេសាទសហគមន៍ **បឹងឡាង** មានទំហំ **៧០៩** ហិកតា និងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

មានព្រំប្រទល់ :

- ខាងជើងទល់នឹង **ភូមិក្អែកពង**
- ខាងត្បូងទល់នឹង **ភូមិខ្លាក្រហឹម**
- ខាងកើតទល់នឹង **ភូមិស្ទឹងស្ងួត** និង **ភូមិអូរម៉ាល់**
- ខាងលិចទល់នឹង **ភូមិក្បាលកោះ** និង **ភូមិកៀនរការ**

### ខ. ដែននេសាទ

កន្លែងនេសាទសហគមន៍ **បឹងឡាង** មានបឹងចំនួន **៣** ព្រែកចំនួន **៤** ប្រឡាយចំនួន **៣**ត្រពាំងចំនួន **១** បៀចំនួន **គ្មាន**។

- បឹងឈ្មោះ **បឹងឡាង** ទំហំ ៣១៥០០០ ម នេសាទពីខែ មករា ដល់ខែ កក្កដា
- អូរឈ្មោះ **អូរអាស្រមតូច** ទំហំ ៣០០ ម នេសាទពីខែ ដល់ខែ
- ព្រែកឈ្មោះ **បែកចាន** ប្រវែង ៥០០ ម នេសាទពីខែ កក្កដា ដល់ខែ សីហា
- ប្រឡាយឈ្មោះ **ទួលតាសេក** ប្រវែង ៣៥០ ម នេសាទពីខែ មិនា ដល់ខែ មិថុនា
- ត្រពាំងឈ្មោះ **កន្លែងត្រឡោក** ទំហំ ៤០០ ហិកតា នេសាទ ពីខែ មិថុនា ដល់ខែ តុលា

**គ. តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស**

- បឹងឈ្មោះ **បឹងឡាង** ទំហំ ២ ហិកតា ( បណ្តោយ ៤០០ ម ទទឹង ៥០ម )

**ឃ. ធនធានជលផល**

- ប្រភេទត្រី ( ត្រីរ៉ស់ ឆ្តោ រៀល ឡៅ ក្រាញ់ ក្រុស កំភ្លៀវ កន្ធរ អណ្តែង កញ្ចុះ ស្លាត កញ្ចនជ័យ ច្រកែង ក្រម៉ម ផ្ទោង កញ្ចាញ់ច្រាស់ អន្ទត់ប្រាក់ ព្រលូង កន្ត្រងប្រេង កន្ត្រប់ ពោ អំពិលទុំ ឆ្មារ ព្រួល ប្រា កែ កាប ក្អែក ផ្កាត ក្រាយ ខ្នាន់ ក្រុមទន្សាយ ក្រុមមាស ច្រវ៉ា ក្លាំងហាយ ក្រពាត់ ខ្ទឹង ឆ្លូញ ឆ្លាំង ព្រួម ក្អុក បណ្តូលចេក កញ្ជ្រៀច កញ្ជ្រូក )
- **ប្រភេទវារីសត្វ** ( អណ្តើក ពស់ ក្តាម )
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ( រាំង ត្រស់ តួ ព្រលិត ត្រកួន ) ( ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទីភ្ជាប់មកជាមួយ ) ។
- **ប្រភេទសៅ្ម**

  ចំបួង,កំពីងពួយ,ក្រធែត,ត្រកួន,ប្រលិត,កន្នាំងហៃ,ល្ពាក់ទឹក,សារាយ,ចក,កំប្លោក,កក់,ស្គុន
- **រាប់ពីរុក្ខជាតិដុះក្នុងបឹង**
- រាំង,ត្រស់ឧម,ត្រសេក,ភ្នំភ្លែង,ប្របួយ,ឡាបគុយ,ធ្មើមអណ្តើក,ទ្រនុងប្រគួយ,ក្របាស់ព្រៃ,ជើងទាន, អញ្ចាញ,ប្រឡាគ្លេ,ត្រអូរ,ទ្រនំអែអូតស្វាព្រាម,ប្រឡាស្អិត,ប្រធិញញី,ប្រធិញឈ្មោល,វល្លិដូងព្រះ,វល្លិជុយ វល្លិព្រេង,វល្លិសឹត,ដើមអាវក្រពើ,ដើមចង្អែង ។

**៤. ការធ្វើនេសាទ**

**ក. អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ២០០ នាក់ ស្រី ១៥ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៣០ នាក់ស្រី គ្មាន
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៤០ នាក់ស្រី គ្មាន

**៦. ឧបករណ៍នេសាទ**

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទៈ

| **ប្រភេទឧបករណ៍** | **ឯកតា** | **ចំនួន** | **ទំហំ/ប្រវែង** | **រដូវប្រើប្រាស់ឧបករណ៍** |
|---|---|---|---|---|
| មង | ១ដៃ=៥០ម | ៤០០=២០០ x2ដៃ | ក្រឡា=៣.៥ ស.ម<br>ជំរៅ=១.៣ម<br>ប្រវែង=២០ ០០០ម | មិថុនា - ធ្នូ |

| | | | | |
|---|---|---|---|---|
| អួន | ម | ១០នាក់ | ១០០០ម | មិថុនា - ធ្នូ |
| សន្ទូចរនង | ផ្លែ | ២០នាក់ | ៤០០០ផ្លែ | មិថុនា - ធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូក ចែវ | ៤០ | ២០០ គក្រ | |
| ទូក ម៉ាស៊ីន | ១៥ | ៨០០ គក្រ-២០០០គក្រ | ៥សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មង | ១ដៃ=៦០ម | ៦=៣នាក់ x ២ដៃ | ក្រឡា=២.៥ស.ម-៣.៥ស.ម<br>ជំរៅ=១.៣ម<br>ក្រឡា=៣៦០ម |
| សន្ទូចរនង | ផ្លែ | ១០នាក់ | ២០០០ផ្លែ |
| លប | គ្រឿង | ៦០នាក់ | ១២០គ្រឿង |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ៥ | ២០០ គក្រ | |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មុង | ១ដៃ=៦០ម | ៦០=៣០នាក់ x2ដៃ | ក្រឡា=២.៥ស.ម-៣.៥ស.ម<br>ជំរៅ=១.៥ម<br>ប្រវែង=៣៦០០ម |
| សន្ទូចរនង | ផ្លែ | ២៥នាក់ | ៥០០០ផ្លែ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកត្នោត | ១០០ | ១០០គីឡូក្រាម | |

## គ. ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ *(គិតជា គក)* | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រី | ៣៦០០០ គក្រ | ៥៤០ គក្រ | ៣៦៥៤០ គក្រ |

## ៥. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក. ទស្សនៈវិស័យ

សហគមន៍នេសាទ **បែកចាន** មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ និងចិរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ. គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬ កាត់បន្ថយពីនាទីឡូត៍នេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬសហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុងទំនាបលិចទឹកក្នុងរដូវជំឡើង នាទីព្រៃលិចទឹក
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

### គ. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ.១- ផែនការប្រើប្រាស់ឧបករណ៍នេសាទ:

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម:

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| បឹង ឡាង បែកចាន | មិថុនា-កញ្ញា | ១ដៃ=៦០ម | ៣០០=១៥០នាក់X២ដៃ | ជំរៅ=១.៥<br>ក្រ មឡា=៣.៥ ស.ម<br>ប្រវែង=១៨០០០ | |
| បឹងកក់ | | លប | ៥នាក់ | ៤០លប | |

## គ.២ ផែនការកែលំអដែននេសាទ

ផែនការកែលំអដែននេសាទត្រូវបានរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលំអ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងឡាង | ៣១៥ H | ៣៦០០ម$^{៣}$ | លើកទំនប់ | ៤/២០០៩ | ២/២០១០ | |
| បឹងឡាង | ៣១៥ ហត | ១០.៥ហត | ដាំកូនឈើ | ២/២០០៩ | ៥/ ២០១០ | |

## គ.៣ ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| បឹងឡាង | ៤៥០០ម$^{២}$ | ធនធានធម្មជាតិមានជីវចំរុះ | ដាក់លូបោះបង្គោលខ្សែលួស ផ្លាកសញ្ញា | កក្កដា ២០០៩ | សីហា ២០០៩ | |

## គ.៤ ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំនិងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | ១០.៥ហត | | ដាំកូនឈើ | មិនា ២០០៩ | ឧសភា ២០០៩ | |

| | | | | | | |
|---|---|---|---|---|---|---|
| ២-ថែរក្សា និង រំលោះព្រៃលិចទឹក | | ទុកកន្លែងត្រីពងកូន | | | | |

### គ.៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម

ផែនការអភិវឌ្ឍន៍វារីវប្បកម្មត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ប្រភេទវារីវប្បកម្ម | ចំនួន | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| ស្រះ | ១០០ | អណ្តែង | ១០គក្រ | មករា ២០០៩ | មិនា ២០០៩ |

### គ-៦ ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | រកថវិកា | ឧសភា ២០០៩ | សីហា ២០០៩ | ១៥៩០០០រ | |

### គ-៧ ផែនការសុខភាព និងអនាម័យ

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ពាងយក្ស | ២០ | ២០ពាង | ១០០ ដុល្លារ | ឧសភា ២០០៩ | កក្កដា ២០០៩ |
| ផ្តល់ធុងចម្រុះទឹកស្អាត | ៤០ | ៤០ធុង | ៤០០ដុល្លារ | មករា ២០១០ | មករា ២០១០ |

### គ-៨ ផែនការទ្រទ្រង់ជីវភាព

| ប្រភេទសកម្មភាព | ចំនួនគ្រួសារ | បរិមាណ | ចំនួនថវិកា | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | បញ្ចប់ |
| ផ្តល់គ្រាប់ពូជបន្លែ | ៥០ | ២៥ កញ្ចប់ | ៥០ ដុល្លា | វិច្ឆិកា ២០០៩ | កក្កដា ២០១០ |
| ផ្តល់មាន់ចិញ្ចឹម | ៣០ | ៩០ ក្បាល | ៣៦០ ដុល្លារ | វិច្ឆិកា ២០០៩ | ធ្នូ ២០០៩ |
| ផ្តល់ជ្រូក | ៣០ | ៣០ ក្បាល | ៩០០ ដុល្លារ | វិច្ឆិកា ២០០៩ | ធ្នូ ២០០៩ |

### គ-៧ ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាពសហគមន៍

| ប្រភេទមុខរបរ | សកម្មភាព និងចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|
| ចិញ្ចឹម ត្រី, ជ្រូក, មាន់ | មាន់ ៣ក្បាល/គ្រួសារ (១០គ្រួសារ)<br>ជ្រូក២ក្បាល/គ្រួសារ (១០គ្រួសារ) | ២០០៩ | ២០១០ |

| | | | |
|---|---|---|---|
| ដាំបន្លែ ( ននោង, សណ្តែកគួ, សៃខៀវ, ស្ពៃចង្កឹះ ) | ២០ គ្រួសារ | ២០០៩ | ២០១០ |
| បណ្តុះផ្សិត | ១គ្រួសារ/២វង ( ១០គ្រួសារ ) | ២០០៩ | ២០១០ |

## គ-៨ ផែនការបោះបង្គោលព្រំប្រទល់សហគមន៍

| ចំនួនបង្គោល | ចំណុចត្រូវបោះ | អ្នកទទួលខុសត្រូវ | ពេលវេលា | | ផ្សេងៗ |
|---|---|---|---|---|---|
| | | | ចាប់ផ្តើម | បញ្ចប់ | |
| ៩ បង្គោល | តាមចំណុចដែលបានកំនត់ក្នុងផែនទីសហគមន៍ | គណៈកម្មការសហគមន៍នេសាទ | កុម្ភៈ ២០០៩ | មិនា ២០០៩ | ត្រូវការជំនួយ និងការសហការពី ស្ថាប័នជំនាញ និងអង្គការនានា |

## គ-៩ ផែនការផ្សព្វផ្សាយ និងលើកកំពស់ការយល់ដឹង

| ប្រធានបទ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|
| លក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៣ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| សារៈប្រយោជន៍នៃធនធានធម្មជាតិ និងបរិស្ថាន | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| ផែនទីកំណត់ព្រំប្រទល់កន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៨ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| ផែនការគ្រប់គ្រងកន្លែងនេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| ច្បាប់ជលផល និងច្បាប់ផ្សេងៗទាក់ទងដល់ការគ្រប់គ្រងសហគមន៍នេសាទ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ៥ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| ការគ្រប់គ្រង និងសារៈប្រយោជន៍នៃព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ១ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |
| ផលប៉ះពាល់ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ | សមាជិក និង គណៈកម្មការស.ន | រៀងរាល់ខែ ២ នៃឆ្នាំនិមួយៗ | ខណ្ឌរដ្ឋបាលជលផល CFC |

### គ-១០ ផែនការពង្រឹងសមត្ថភាពសហគមន៍

| ផែនការ | ប្រធានបទ/ជំនាញ | ក្រុមគោលដៅ | ពេលវេលា | អ្នកទទួលខុសត្រូវ |
|---|---|---|---|---|
| ពង្រឹងស្ថាប័ន និង ការងារគ្រប់គ្រង | ការធ្វើកំណត់ហេតុ និង របាយការណ៍ | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | របៀបសរសេរខិតរដ្ឋបាល | គណៈកម្មការស.ន | កក្កដា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | រៀបចំទុកដាក់ឯកសារសហគមន៍ និងរបៀបកត់ត្រាប្រចាំថ្ងៃ | គណៈកម្មការស.ន | មិថុនា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | ការគ្រប់គ្រងថវិកា | គណៈកម្មការស.ន | កុម្ភៈ ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | ការដោះស្រាយទំនាស់ | គណៈកម្មការស.ន | | ខណ្ឌរដ្ឋបាលជលផល CFC |
| | ការទំនាក់ទំនង និង សរសេរសំណើសុំថវិកា | គណៈកម្មការស.ន | មេសា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | រៀបចំបណ្តាញសហគមន៍ | គណៈកម្មការស.ន | សីហា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | ទស្សនៈកិច្ចសិក្សាផ្លាស់ប្តូរ បទពិសោធន៍ | គណៈកម្មការស.ន | ១ ដង / ឆ្នាំ | ខណ្ឌរដ្ឋបាលជលផល CFC |
| បណ្តុះបណ្តាល បច្ចេកទេស | បណ្តុះ និងដាំព្រៃលិចទឹក | សមាជិក និង គណៈកម្មការស.ន | កញ្ញា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | ចិញ្ចឹមត្រី និងសត្វ | សមាជិក និង គណៈកម្មការស.ន | កុម្ភៈ ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |
| | បណ្តុះផ្សិត | សមាជិក និង គណៈកម្មការស.ន | មិនា ២០០៩ | ខណ្ឌរដ្ឋបាលជលផល CFC |

## ឃ. យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៏ផែនការ រួមមានៈ សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកសហគមន៍នេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អ ជាពិសេសអំពីបញ្ហានេសាទ

- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនឹងបច្ចេកទេសជលផលដូចជា: ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការស្តារព្រៃក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសំរាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសមត្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | - ផ្សព្វផ្សាយផែនការប្រើប្រាស់ឧបករណ៍នេសាទដល់សមាជិកសហគមន៍ទាំងអស់ និងអ្នកមកពីខាងក្រៅ<br>- ចុះត្រួតពិនិត្យ និងតាមដានជាប្រចាំ | - សមាជិក និងអ្នកមិនមែនជាសមាជិកសហគមន៍ទាំងអស់បានជ្រួតជ្រាបពីផែនការ<br>- ការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ថយចុះ នាំឱ្យត្រីមានការកើនឡើង | - ចំណាយលើការផ្សព្វផ្សាយ ១៥០ ដុល្លា<br>- ចំណាយលើការចុះ<br>- ល្បាត ត្រួតពិនិត្យតាមដាន ២០០ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ប្រាក់បដិភាគរបស់សហគមន៍ | ២០០៩ | ២០១០ | |
| ២. ការកែលំអដែននេសាទ | - លើកទំនប់ | - សមាជិកសហគមន៍នឹងទទួលផលប្រយោជន៍ពីការប្រើប្រាស់ទឹក និងធនធានធម្មជាតិ ជាពិសេសត្រីពីក្នុងបឹង | - ចំណាយសរុប ៣០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មេសា ២០០៩-២០១០ | ឧសភា ២០០៩ | |
| ៣. ការកំណត់ និងរៀបចំតំបន់អភិរក្ស | - ពិភាក្សាជាមួយសមាជិកសហគមន៍ ដើម្បីចុះកំនត់តំបន់អភិរក្សជាក់ស្តែង<br>- សុំការគាំទ្រពីអាជ្ញាធរភូមិ-ឃុំ<br>- រៀបចំសំណើសុំថវិកា និងស្វែងរកការគាំទ្រ<br>- ចុះកំណត់ព្រំប្រទល់, បោះបង្គោល, ដាក់ស្លាកសញ្ញា, ទំលាក់លូនិងគល់ឈើ<br>- ចុះយាមល្បាតតាមផែនការ | - បឹងឡាង និងត្រូវកំនត់ជាកន្លែងអភិរក្សត្រីមេពូជ<br>- ព្រៃលិចទឹកជុំវិញបឹងឡាង ចំនួន ៤៥០០ម២ នឹងត្រូវដាក់ជា ព្រៃអភិរក្ស<br>- ធនធានធម្មជាតិ ( ត្រី, ព្រៃលិចទឹក និងសត្វគ្រប់ប្រភេទ) នឹងកើនឡើង | - ចំណាយសរុប ២៥០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | កក្កដា ២០០៩ | សីហា ២០០៨ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤-ផែនការគ្រប់គ្រងព្រៃលិចទឹក | - ផ្សព្វផ្សាយពីសារប្រយោជន៍ព្រៃលិចទឹកជាសាធារណៈ ។<br>- កំណត់កន្លែងត្រូវដាំព្រៃលិចទឹក និងយុទ្ធនាការដាំ<br>- ដាក់ស្លាកសញ្ញាហាមកាប់បំផ្លាញព្រៃលិចទឹក និងត្រួតពិនិត្យឃ្លាំមើល | - ត្រូវបានកំនត់ជា តំបន់ដែលត្រូវដាំព្រៃឡើងវិញ<br>- កូនឈើចំនួន ៥០០០ដើមត្រូវបានបណ្ដុះ និងដាំ | - ចំណាយសរុប ១០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មិនា ២០០៩ | ឧសភា ២០០៨ | |
| ៥- ផែនការអភិវឌ្ឍន៍វារីវប្បកម្ម | - ផ្សព្វផ្សាយពីការចិញ្ចឹមត្រីក្នុងស្រះ និងជីករណ្ដៅដាក់ថង់ផ្លាស្ទិក | - សហគមន៍ចំនួន១០០គ្រួសារសាកល្បងអនុវត្តការចិញ្ចឹមត្រី ក្នុងស្រះ និងជីករណ្ដៅដាក់ថង់ផ្លាស្ទិកជាមួយនិងកូនត្រីអណ្ដែង<br>- ពូជ ចំនួន ១០គក្រ | - ចំណាយសរុប ១៥០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | មិនា ២០០៨ | |
| ៦- ផែនការរកប្រាក់ចំណូលសហគមន៍ | - ប្រមូលប្រាក់សមាជិកភាព និងភាគទានប្រចាំឆ្នាំ<br>- ស្វែងរកជំនួយបន្ថែមពីអង្គការ និងសប្បុរសជននានា | - សមាជិកស.នទាំងអស់នឹងបង់ប្រាក់តាមការកំនត់ក្នុងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង<br>- អង្គការ និងសប្បុរសជននានានឹងជួយគាំទ្រតាមរយៈការផ្ដល់សំភារៈ និងថវិកាដល់ស.ន | - គ្មានការចំណាយ | - | មិនា ២០០៩ | សីហា ២០០៨ | |
| ៧-ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | - វិភាគ និងចាត់អាទិភាពជំរើសមុខរបរចិញ្ចឹមជីវិត | - ជំរើសមុខរបរចិញ្ចឹមជីវិតត្រូវបានកំនត់ និងចាត់អាទិភាព | - ចំណាយសរុប ៥០០០ ដុល្លា | - ជំនួយអង្គការ និងសប្បុរសជននានា | ២០០៩-២០១០ | ២០១០ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | - រៀបចំសំណើសុំថវិកា | និងទទួលបានការគាំទ្រពីអង្គការនានា | | - ប្រាក់បដិភាគរបស់សហគមន៍ | | | |
| ៨- ផែនការបោះបង្គោលព្រំប្រទល់សហគមន៍ | - សហការជាមួយជំនាញផែនទីកំនត់ទីតាំងត្រូវបោះបង្គោល<br>- ស្វែងរកថវិកាគាំទ្រ | - បង្គោលត្រូវបានបោះត្រឹមត្រូវតាមចំនុចដែលកំនត់លើផែនទី<br>- ស.នមានព្រំប្រទល់ច្បាស់លាស់កាត់បន្ថយជម្លោះ | - ចំណាយសរុប ៣០០ ដុល្លា | - ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មិនា ២០០៩ | មិនា ២០០៨ | |
| ៩- ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | - ផ្សព្វផ្សាយឱ្យស.គបានយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ច្បាប់និងលិខិតបទដ្ឋានផ្សេងៗពាក់ព័ន្ធនិងស.ន | - ស.គបានយល់ដឹង និងអនុវត្តតាម | - ១០០ ដុល្លា | - ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មករា ២០០៩ | ធ្នូ ២០១០ | |
| ១០- ផែនការពង្រឹងសមត្ថភាពសហគមន៍ | - បង្កើនសមត្ថភាពស.គទាំងជំនាញគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ស.គចេះជំនាញផ្សេងៗទាក់ទិននិងការងារគ្រប់គ្រងស្ថាប័ន និងបច្ចេកទេស | - ១០០ ដុល្លា | - ជំនួយអង្គការនិងសប្បុរសជននានា<br>- ថវិកាអភិវឌ្ឍន៍ឃុំ<br>- ប្រាក់បដិភាគរបស់សហគមន៍ | មេសា ២០០៩ | ធ្នូ ២០០៨ | |

## តារាងកម្មវិធីការងារ

| សកម្មភាព | ឆ្នាំ ២០០៨ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | ■ | ■ | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | ■ | ■ | ■ | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | ■ | ■ | ■ | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | ■ | ■ | ■ | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | ■ | ■ | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |

| សកម្មភាព | ឆ្នាំ ២០០៩ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | ■ | ■ | ■ | ■ | ■ | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | | | | | | | | | | | | |

| សកម្មភាព | ឆ្នាំ ២០១០ 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១. ការប្រើប្រាស់ឧបករណ៍នេសាទ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ២. ការកែលំអដែននេសាទ | | | | | | | | | | | | |
| ៣. ការកំណត់ និង រៀបចំតំបន់អភិរក្ស | | | | | | | | | | | | |
| ៤. ផែនការគ្រប់គ្រងព្រៃលិចទឹក | | | | | | | | | | | | |
| ៥. ផែនការអភិវឌ្ឍន៍វារីវប្បកម្មតាមស្រះ | | | | | | | | | | | | |
| ៦. ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍ | | | | | | | | | | | | |
| ៧. ផែនការបង្កើនមុខរបរទ្រទ្រង់ជីវភាព | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ៨. ផែនការបោះបង្គោលព្រំប្រទល់ស.គ | | | | | | | | | | | | |
| ៩. ផែនការផ្សព្វផ្សាយនិងបង្កើនការយល់ដឹង | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ១០. ផែនការពង្រឹងសមត្ថភាពសហគមន៍ | | | | | | | | | | | | |

បានឃើញ និងបញ្ជូនមក

លោកនាយ...រដ្ឋបាលជលផល

**នាយសង្កាត់រដ្ឋបាលជលផល**..........

..........ថ្ងៃទី...10...ខែ...9...ឆ្នាំ ២០០8

លេខ :................

បានឃើញ

**មេឃុំ**..........

..........ថ្ងៃទី...10...ខែ...9...ឆ្នាំ ២០០8

លេខ :...446...

..........ថ្ងៃទី...8...ខែ...9...ឆ្នាំ ២០០8

**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ :...02...

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ ២០០

**ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា**

**ប្រធានរដ្ឋបាលជលផល**

បានឃើញ និងបញ្ជូនមក

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា

ប្រធានរដ្ឋបាលជលផល

" ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ "

..........ថ្ងៃទី...27...ខែ...11...ឆ្នាំ ២០០ 8

**នាយអធិការដ្ឋាន...រដ្ឋបាលជលផល**..........

បានឃើញ និងបញ្ជូនមក

លោកនាយអធិការដ្ឋាន...រដ្ឋបាលជលផល..........

..........ថ្ងៃទី...21...ខែ...10...ឆ្នាំ ២០០8

**នាយខណ្ឌរដ្ឋបាលជលផល**..........